01328350

E439/3

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Sep-2016, 16:00
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញានៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំសេចក្តីបញ្ជាក់ទាក់ទងនឹងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង០០២

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះសាលាដំបូង:**
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យ៉ា សុខន
ចៅក្រម Claudia FENZ
ចៅក្រម យូរ ឧត្តារា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
ពេជ អង្គ
Marie GUIRAUD

**ចម្លងជូន:**
**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន
**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
**មេធាវីប្រចាំការ:**
លោកស្រី ទូច វរល័ក្ស
លោក Calvin SAUNDERS

## សេចក្តីផ្តើម

1. សហព្រះរាជអាជ្ញា សូមឆ្លើយតបទៅនឹងសំណើរបស់ "សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំការបញ្ជាក់ពាក់ព័ន្ធនឹងការចោទប្រកាន់នៅក្នុងសំណុំរឿង០០២ ដែលនៅសេសសល់" ដែលបានដាក់នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១៦ ("សំណើ")[1]។

2. សហព្រះរាជអាជ្ញាគោរពសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ នៅក្នុងសំណុំរឿង០០២ ចំពោះព័ត៌មានទាន់ពេល និងមានតម្លាភាព ពាក់ព័ន្ធនឹងការជឿនលឿនទៅមុខនៃសំណុំរឿង០០២។ បន្ថែមលើនេះ សហព្រះរាជអាជ្ញាយល់ស្របថា វាជាប្រយោជន៍របស់ភាគីទាំងអស់ និង អ.វ.ត.ក ដែលជាស្ថាប័នមួយ មានភាពច្បាស់លាស់លើបញ្ហានៃការចោទប្រកាន់តាមអង្គហេតុ នៅសេសសល់ ដែលមិនបានគ្របដណ្តប់ដោយសំណុំរឿង០០២/០១ និង០០២/០២។

3. មិនមានការជំនុំជម្រះ ក្នុងរយៈពេលណាមួយ អាចឆ្លុះបញ្ចាំងទាំងស្រុងនូវវិសាលភាពពិតនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តប្រឆាំងនឹងការឈឺចាប់ដែលបានធ្វើទៅលើស្ត្រី កូនក្មេង និងបុរសរាប់លាននាក់ ដោយពួកមេដឹកនាំនៃ បកក នៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ យ៉ាងណាក៏ដោយ ការជំនុំជម្រះទាំងអស់ត្រូវតែបញ្ចប់។ ការណ៍នេះគឺជាប្រយោជន៍របស់ជនរងគ្រោះទាំងអស់។ ដូចដែលអង្គជំនុំជម្រះសាលាដំបូង បានកត់សម្គាល់ថា "កិច្ចដំណើរការនីតិវិធីជំនុំជម្រះដែលអូសបន្លាយពេលយូរ ប៉ុន្តែចុងក្រោយ មិនបានទទួលលទ្ធផលនោះ អាចនាំឲ្យមានការខកចិត្តយ៉ាងខ្លាំងសម្រាប់ជនរងគ្រោះច្រើនពីឧក្រិដ្ឋកម្មក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានរង់ចាំយុត្តិធម៌អស់រយៈពេលបីទសវត្សរ៍ សម្រាប់ភាគីនានានៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក និងប្រទេសផ្តល់ជំនួយនានាដែលបានចំណាយធនធានជាច្រើននៅ អ.វ.ត.ក ក្នុងរយៈពេលជាច្រើនឆ្នាំ ក៏ដូចជាសាធារណជនទូទៅផងដែរ"[2]។

---

[1] **E439** សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំសេចក្តីបញ្ជាក់ទាក់ទងនឹងបទចោទដែលនៅ សេសសល់ក្នុងសំណុំរឿង០០២, ៩ កញ្ញា ២០១៦។

[2] **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់ អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, កថាខណ្ឌ ១៣៧។

4. សេចក្តីសម្រេចដើម្បីដកចេញនូវព្រឹត្តិការណ៍ ឬទីកន្លែងឧក្រិដ្ឋកម្មមួយចំនួនពីវិសាលភាពនៃសវនាការបច្ចុប្បន្ន នឹងចៀសមិនផុតធ្វើឱ្យជនរងគ្រោះខកចិត្តចំពោះឧក្រិដ្ឋកម្មខ្លះក្នុងចំណោមឧក្រិដ្ឋកម្មទាំងនោះ។ ការកំណត់ថាតើទីកន្លែងឧក្រិដ្ឋកម្មណាត្រូវដាក់បញ្ចូល ហើយថាតើទីកន្លែងឧក្រិដ្ឋកម្មណាត្រូវដកចេញ មានជាប់ទាក់ទងទៅនឹង, ដូចជា អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថា គឺ "អាចប៉ះពាល់ដល់តុល្យភាពនៃការពិចារណានេះ"[3]។

5. ដោយសារសវនាការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០១ បានចាប់ផ្តើមជិតប្រាំឆ្នាំមកហើយ សហព្រះរាជអាជ្ញាបានគិតពីការចាំបាច់ដើម្បីធានាថាព្រឹត្តិការណ៍ទាំងឡាយដែលបានពិនិត្យនៅក្នុងសំណុំរឿង០០២ គឺជាតំណាងសមហេតុសមផលនៃវិសាលភាពពិតនៃការទទួលខុសត្រូវខាង ព្រហ្មទណ្ឌរបស់ជនជាប់ចោទ។ ដូចដែលបានចែងនៅក្នុងសេចក្តីពិស្តារខាងក្រោម សហព្រះរាជអាជ្ញានៅខែធ្នូ ឆ្នាំ២០១៣ បានស្នើឱ្យដាក់បញ្ចូល និងដកចេញនូវអង្គហេតុមួយចំនួនពីវិសាលភាពនៃសំណុំរឿង០០២/០២។ សហព្រះរាជអាជ្ញាបានបញ្ជាក់ជាសាធារណៈនៅពេលនោះ ថាសហព្រះរាជអាជ្ញាមិននឹកក្នុងចិត្តថាមានសវនាការទីបីមួយទៀតពាក់ព័ន្ធនឹងអង្គហេតុដែលបានដកចេញទាំងនោះទេ។ នៅពេលដែលសវនាការបច្ចុប្បន្ននេះចប់ អង្គជំនុំជម្រះសាលាដំបូងនឹងបានទទួលនូវឯកសារ និងភស្តុតាងជាសក្ខីកម្មមួយចំនួនពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដ៏រង្គាលដែលបានប្រព្រឹត្តប្រឆាំង នឹងខ្មែរ ចាម និងវៀតណាម នៅស្ទើរតែគ្រប់ទីកន្លែងទាំងអស់នៃប្រទេសកម្ពុជា។ ភស្តុតាងនោះ គឺជាតំណាងសមហេតុសមផលនៃភាពទាំងស្រុង នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ជនជាប់ចោទ។

6. នៅក្នុងកាលៈទេសៈទាំងនេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា ជាជាប្រយោជន៍នៃយុត្តិធម៌ និងជាប្រសិទ្ធភាពសម្រាប់អង្គជំនុំជម្រះសាលាដំបូងចេញដីកា ដោយយោងទៅតាមវិធាន៨៩*ស្ទួនបី* ការបញ្ចប់កិច្ចដំណើរការនីតិវិធីទាក់ទងនឹងអង្គហេតុដែលបានដកចេញពីវិសាលភាព នៃសំណុំរឿង០០២/០២។ ការណ៍នេះនឹងមិនប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ណាមួយនៅក្នុងសំណុំរឿង០០២នោះទេ ហើយនឹងជួយសម្រួលដល់សេចក្តីសន្និដ្ឋានមានរបៀបរៀបរយ និងថ្លៃថ្នូរនៃសវនាការទៀតផង។

[3] **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, កថាខណ្ឌ ១១៥។

**សទនាការលើសំណុំរឿង០០២/០១ និង០០២/០២ ឆ្លុះបញ្ចាំងសមហេតុសមផលពីវិសាលភាព និងចរិតលក្ខណៈនៃភាពទាំងស្រុងនៃអំពើឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ និងពិរុទ្ធភាពខាងបុគ្គលរបស់ជនជាប់ចោទ**

7. នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់នូវសេចក្តីណែនាំថា "ការបញ្ចូលគ្នានៃសំណុំរឿង០០២/០១ និង០០២/០២ នឹងក្លាយជាតំណាងសមហេតុផលនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[4]។ អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅដល់បទប្បញ្ញត្តិទាំងឡាយពីទម្រង់បែបបទច្បាប់នៃតុលាការយោធាអន្តរជាតិនៅ Nuremberg, តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេស Yugoslavia ("ICTY"), តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេស Rwanda, តុលាការពិសេសសម្រាប់ប្រទេស Sierra Leone ("SCSL"), និងតុលាការព្រហ្មទណ្ឌអន្តរជាតិ ហើយបានថ្លែងថា៖ "នៅសាលាក្តីអន្តរជាតិ ឬសាលាជំនុំជម្រះចម្រុះព្រហ្មទណ្ឌជាតិ និងអន្តរជាតិ ការចោទប្រកាន់ជាលក្ខខណ្ឌចាំបាច់ គឺកម្រិតត្រឹមតែផ្តល់ផលប្រយោជន៍ដល់ការចោទប្រកាន់ដែលមានលក្ខណៈជ្រើសរើសលើបុគ្គលមួយចំនួនក្នុងចំណោម "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយផ្តោតលើគោលនយោបាយដែលធ្វើឲ្យមានតុល្យភាពនូវគោលដៅនៃយុត្តិធម៌រឿងព្រហ្មទណ្ឌជាមួយនឹងធនធានដែលមានកម្រិត"[5]។

8. អង្គជំនុំជម្រះតុលាការកំពូលក៏បានកត់សម្គាល់ផងដែរថា ICTY និង SCSL បានធ្វើវិសោធនកម្មលើវិធានរបស់ពួកគេដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងរបស់ពួកគេ អញ្ជើញរដ្ឋអាជ្ញាឲ្យកាត់បន្ថយ ឬការចេញដីកាកាត់បន្ថយ *តាមគំនិតផ្ទាល់ខ្លួន* នូវបទចោទមួយចំនួននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬកំណត់ចំនួនទីកន្លែងឧក្រិដ្ឋកម្ម ឬព្រឹត្តិការណ៍ ទាក់ទងទៅនឹងរឿងទាំងនោះភស្តុតាងអាចនឹងត្រូវបានបង្ហាញ[6]។ អង្គជំនុំជម្រះតុលាការកំពូលបានថ្លែងថា គោលការណ៍ដែលគ្រប់គ្រងលើការកាត់បន្ថយបទចោទនៅក្នុងករណីបែបដូច្នេះ ដូចជាលក្ខណៈវិនិច្ឆ័យលើភាពជា

[4] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌ ៧០។

[5] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌ៦១។

[6] **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌ៦៣។

តំណាង ក្លាយទៅជាអាចប្រដូចបាន និងពាក់ព័ន្ធ[7]។ អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា៖ "គោលបំណងសំខាន់បំផុតនៃលក្ខខណ្ឌនៃភាពជាតំណាង គឺដើម្បីជ្រើសរើសបទចោទក្នុងចំនួនអប្បបរមាដែលអាចឆ្លុះបញ្ចាំងសមហេតុផលនូវវិសាលភាព និងចរិតលក្ខណៈ នៃការដាក់បន្ទុកជាលក្ខណៈបុគ្គល និងអំពើឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទាំងមូល"[8]។

9. នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១៣ ដោយយោងទៅតាមសេចក្តីណែនាំរបស់អង្គជំនុំជម្រះតុលាការកំពូល សហព្រះរាជអាជ្ញាបានដាក់សំណើជាសាធារណៈ ទាក់ទងនឹងទីកន្លែងឧក្រិដ្ឋកម្មណាខ្លះដែលត្រូវដាក់បញ្ចូល[9] ទីកន្លែងឧក្រិដ្ឋកម្មណាខ្លះដែលត្រូវដកចេញ[10] ពីវិសាលភាពនៃសំណុំរឿង០០២/០២ ដើម្បីធានាថា សវនាការលើសំណុំរឿង០០២/០២- ដោយរួមគ្នាជាមួយនឹងសវនាការលើសំណុំរឿង ០០២/០១- គឺជាតំណាងសមហេតុសមផលនៃពិរុទ្ធភាពដែលបានចែងនៅក្នុងដីកាដំណោះស្រាយ។ ព្រឹត្តិការណ៍ដែលបានស្នើឡើងសម្រាប់ការដកចេញ គឺជាឧទាហរណ៍បង្គ្រប់បន្ថែមក្រោយទៀត នៃទីកន្លែងដែលឧក្រិដ្ឋកម្ម ត្រូវបានប្រព្រឹត្ត ដោយការតាមពិនិត្យមើលគោលនយោបាយថ្នាក់ជាតិ ដែលនៅចំកណ្តាលបេះដូងនៃសហឧក្រិដ្ឋកម្មរួមដែលបានចោទប្រកាន់។ ដូចដែលបានពិភាក្សា

---

7 **E284/4/8** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌ៦៣។

8 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២, ២៥ វិច្ឆិកា ២០១៣, កថាខណ្ឌ៦៤។

9 សហព្រះរាជអាជ្ញាផ្តល់អនុសាសន៍ថា ទីកន្លែងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ដូចតទៅនេះ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ០០២/០២៖ (១) មន្ទីរសន្តិសុខស-២១ រួមទាំង ជើងឯក។ (២) ប្រព្រឹត្តិកម្មលើជនជាតិវៀតណាម (ដកចេញនូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយកងទ័ពបដិវត្តកម្ពុជាទៅក្នុងទឹកដីវៀតណាម)។ (៣) ប្រព្រឹត្តិកម្មលើជនជាតិចាម (ដកចេញនូវមន្ទីរសន្តិសុខក្រូចឆ្មារ)។ (៤) សហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ រួមទាំង ប្រព្រឹត្តិកម្មលើព្រះពុទ្ធសាសនិកជន និងអាពាហ៍ពិពាហ៍ដោយបង្ខំ។ (៥) ការដ្ឋានទំនប់ ១ មករា។ (៦) ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង។ (៧) មន្ទីរសន្តិសុខអូរកន្សែង។ និង (៨) មន្ទីរសន្តិសុខភ្នំក្រោល។ **E301/2** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ពន្ធ ក, ៥ ធ្នូ ២០១៣, កថាខណ្ឌ១៨។

10 សហព្រះរាជអាជ្ញាផ្តល់អនុសាសន៍ថា ការដកចេញពីវិសាលភាពនៃសំណុំរឿង០០២/០២ មានដូចតទៅ៖ (១) ការជម្លៀសប្រជាជនដំណាក់កាលទីបី។ (២) ទំនប់ត្រពាំងថ្ម ការដ្ឋានស្រែអំបិល និងព្រៃស។ (៣) មន្ទីរសន្តិសុខសង់ កោះខ្សឹង ព្រៃដំរីស្រុត វត្តគិរីរម្យភូមិភាគឧត្តរ វត្តធ្លក គោកក្តួច និងក្រូចឆ្មារ។ (៤) កន្លែងសម្លាប់មនុស្សនៅស្រុក១២ និងស្ទឹងតូច។ និង (៥) ការជ្រៀតចូលនៃកងទ័ពបដិវត្តកម្ពុជាទៅក្នុងប្រទេសវៀតណាម។ **E301/2** សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ពន្ធ ក, ៥ ធ្នូ ២០១៣, កថាខណ្ឌ២៧។

ខាងក្រោម គោលនយោបាយថ្នាក់ជាតិទាំងនោះ និងការអនុវត្តរបស់វាដោយមធ្យោបាយឧក្រិដ្ឋ ត្រូវបានពិនិត្យទាំងស្រុងនៅក្នុងសវនាការលើសំណុំរឿង០០២/០១ និងសវនាការលើសំណុំរឿង០០២/០២។

10. ដើម្បីតម្លាភាព សហព្រះរាជអាជ្ញាបានធ្វើការបំភ្លឺជាសាធារណៈ ក្នុងខែធ្នូ ឆ្នាំ២០១៣ ថា សហព្រះរាជអាជ្ញាមិនរំពឹងថា សវនាការទីបីសម្រាប់សំណុំរឿង០០២ ទាក់ទងនឹងបញ្ហានេះ នឹងមានឡើយ ដោយបានស្នើកុំឲ្យមានការដាក់បញ្ចូលដូចខាងក្រោម៖

> ដោយមិនគិតពីដំណើរការនីតិវិធីតាមផ្លូវច្បាប់ជាក់លាក់ដែលយកមកអនុវត្តជាចុងក្រោយ ទាក់ទងនឹងទីកន្លែងឧក្រិដ្ឋកម្ម និងឧប្បត្តិហេតុដែលមិនបានដាក់បញ្ចូលនោះទេ សហព្រះរាជអាជ្ញាមិនសង្ឃឹមថានឹងមានសវនាការលើកទីបីពាក់ព័ន្ធទៅនឹងបញ្ហាទាំងនេះ លើជនជាប់ចោទនោះទេ។ សំណុំរឿង០០២/០២ ដោះស្រាយលើគ្រប់ការចោទប្រកាន់នៃឧក្រិដ្ឋកម្មទាំងអស់ដែលនៅសេសសល់ ដែលមាននៅក្នុងដីកាដំណោះស្រាយដែលមិនត្រូវបានគ្រប់ដណ្ដប់នៅក្នុងសំណុំរឿង០០២/០១ ដោយជ្រើសរើសយកទីកន្លែងឧក្រិដ្ឋកម្មជាតំណាងសម្រាប់បទចោទនីមួយៗ។ ដូច្នេះ ដើម្បីផ្ដល់នូវភាពច្បាស់លាស់មួយជូនដល់ជនរងគ្រោះ ជនជាប់ចោទ និងម្ចាស់អំណាយ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សំណុំរឿង០០២/០២ ត្រូវតែជាសវនាការបញ្ចប់លើរឿងក្ដីរបស់ នួន ជា និង ខៀវ សំផន នៅ អ.វ.ត.ក លើដីកាដំណោះស្រាយនៃសំណុំរឿង០០២[11]។

11. នៅថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្ដីសម្រេចមួយ[12]ដែលនៅក្នុងសេចក្ដីសម្រេចនេះ អង្គជំនុំជម្រះបានកំណត់វិសាលភាពនៃសំណុំរឿង០០២/០២ ដើម្បីធានាថាវិសាលភាពនេះត្រូវតែតំណាងឲ្យបទចោទដែលនៅសល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស្របតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣។ អង្គជំនុំជម្រះសាលាដំបូង មិនបានដោះស្រាយឲ្យបានច្បាស់លាស់លើបញ្ហានៃការដកចេញបទចោទនានាទេ មួយចំណែកគឺដោយសារមូលហេតុថា ខ្លួនមិនត្រូវបានប្ដឹងតាមសំណើណាមួយពីសហព្រះរាជ

---

[11] **E301/2** សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងវិសាលភាពនៃសំណុំរឿង០០២/០២ និងការកំណត់កាលបរិច្ឆេទសវនាការ រួមជាមួយឧបសម្ព័ន្ធ ក, ៥ ធ្នូ ២០១៣, កថាខណ្ឌ២៨។

[12] **E301/9/1** សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២, ៤ មេសា ២០១៤។

អាជ្ញា និងមួយចំណែកទៀតដោយសារផ្អែកលើមូលហេតុថា កាលនោះមិនទាន់មានបទប្បញ្ញត្តិច្បាប់ច្បាស់លាស់ដែលអនុញ្ញាតសម្រាប់ការដកចេញបទចោទដូច្នេះ[13]។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនេះ ត្រូវបានតម្កល់តាមរយៈបណ្តឹងឧទ្ធរណ៍ដោយអង្គជំនុំជម្រះតុលាការកំពូល នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤[14]។

12. នៅខែមករា ឆ្នាំ២០១៥ ចៅក្រមរបស់ អ.វ.ត.ក នៅក្នុងសម័យប្រជុំពេញអង្គលើកទី១១ របស់ខ្លួនបានអនុម័តវិធាន៨៩*ស្ទួនបី*។ ការណ៍នេះអនុញ្ញាតឱ្យអង្គជំនុំជម្រះសាលាដំបូងកាត់បន្ថយវិសាលភាពនៃសវនាការជំនុំជម្រះ តាមរយៈការដកចេញអង្គហេតុទាំងឡាយ ដូចបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឱ្យតែអង្គហេតុដែលនៅសល់ "តំណាងឱ្យវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ"។ អង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធី ទាក់ទងទៅនឹងអង្គហេតុនានាដែលបានដកចេញ[15]។

13. ជារួម សវនាការនៃសំណុំរឿង០០២/០១ និង០០២/០២ បានគ្របដណ្តប់លើគ្រប់ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងអស់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង០០២ (ថ្វីបើ មិនមែនគ្រប់ទីតាំងទាំងអស់នៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តត្រូវបានត្រួតពិនិត្យក៏ដោយ) ដែលរួមទាំងបញ្ចូល៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភសេពសន្ថវៈ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ និងសាសនា និងអំពើអមនុស្សធម៌ផ្សេងៗទៀត អំពើប្រល័យពូជសាសន៍ តាមរយៈការសម្លាប់សមាជិកនៃក្រុមជនជាតិវៀតណាម និងចាម អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ជាពិសេស ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវ

[13] **E301/9/1** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២, ៤ មេសា ២០១៤, កថាខណ្ឌ៤៥។

[14] **E301/9/1/1/3** សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង០០២ និងវិសាលភាពនៃសំណុំរឿង០០២/០២, ២៩ កក្កដា ២០១៤។

[15] វិធាន៨៩ស្ទួនបី(៣) នៃវិធានផ្ទៃក្នុង។

សិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការនិរទេស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ និងការបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ជាពិសេស ការធ្វើមនុស្សឃាត ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា[16]។

14. ដូចដែលសហព្រះរាជអាជ្ញានឹងធ្វើអំណះអំណាងលម្អិតជាងនេះច្រើនទៀតនៅពេលវេលាមកដល់ការជំនុំជម្រះក្តីនៃសំណុំរឿង០០២/០១ និង០០២/០២ បានបង្ហាញឲ្យឃើញថា មេដឹកនាំ បកក រួមទាំងជនជាប់ចោទផង បានចូលរួមប្រព្រឹត្តក្នុងសហឧក្រិដ្ឋកម្មរួម ដែលមានការពាក់ព័ន្ធនៅក្នុងការបង្កើតគោលនយោបាយនានា ដែលចេញជាលទ្ធផលនៅក្នុងឧក្រិដ្ឋកម្មទាំងនេះ នៅក្នុងវិស័យជាទូទៅ ចំនួនប្រាំដូចខាងក្រោម៖

ក) ការផ្លាស់ទីលំនៅដែលធ្វើឡើងជាច្រើនលើកច្រើនសារទៅលើប្រជាជនចេញពីទីប្រជុំជនទៅកាន់ទីជនបទ និងពីទីជនបទមួយទៅកាន់តំបន់ជនបទមួយផ្សេងទៀត។

ខ) ការបង្កើត និងប្រតិបត្តិការនៃសហករណ៍ និងការដ្ឋាននានា។

គ) ការអប់រំឡើងវិញចំពោះ "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" ទាំងនៅក្នុងជួរ និងក្រៅជួរបក្ស។

ឃ) ការកំណត់គោលដៅលើក្រុមជាក់លាក់នានា ជាពិសេស ជនជាតិចាម ជនជាតិវៀតណាម ពុទ្ធសាសនិក និងអតីតអ្នករដ្ឋការនានានៃសាធារណរដ្ឋខ្មែរ រួមទាំងមន្ត្រីរាជការ និងអតីតបុគ្គលិកយោធា ព្រមទាំងក្រុមគ្រួសាររបស់ពួកគេ; និង

ង) ការដាក់បទបញ្ញាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍[17]។

15. សហព្រះរាជអាជ្ញាសន្និដ្ឋានថា គ្រប់បទចោទប្រកាន់តាមផ្លូវច្បាប់ទាំងអស់ នៅក្នុងដីកាដំណោះស្រាយ និងគ្រប់គោលនយោបាយដែលស្ថិតនៅពីក្រោយនៃសហឧក្រិដ្ឋកម្មរួម ដូចដែលបានចោទប្រកាន់ទាំងអស់ ត្រូវបានសួរដេញដោលពេញលេញនៅក្នុងសវនាការនៃសំណុំរឿង០០២/០១ និង ០០២/០២។ សវនាការទាំងនេះ គឺតំណាងពេញលេញឲ្យបទចោទនានានៅក្នុងដីកាដំណោះស្រាយ។

---

[16] **D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០, កថាខណ្ឌ ១៦១៣។

[17] **D427** ដីកាដំណោះស្រាយ, ១៥ កញ្ញា ២០១០, កថាខណ្ឌ ១៥៧។

## ប្រតិបត្តិការនៃវិធាន៨៩ស្ទួនបី មិនប៉ះពាល់ដល់សិទ្ធិនៃការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ

16. ការបង្គាប់មួយដែលបានធ្វើឡើងតាមវិធាន៨៩ស្ទួនបី មិនប៉ះពាល់ដល់ការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយ ឬសមាសភាពនៃក្រុមរួមនៃភាគីដើមបណ្តឹងរដ្ឋប្បវេណីទេ[18]។ ដូច្នេះ ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលទទួលបានការអនុញ្ញាតឲ្យចូលរួមនៅក្នុងសវនាការ នៃសំណុំរឿង០០២ - រួមទាំងអ្នកទាំងឡាយដែលជាជនរងគ្រោះនៃព្រឹត្តិការណ៍នានាដែលបានដកចេញពីក្នុងវិសាលភាពនៃសំណុំរឿង០០២[19]-នឹងនៅតែបន្តរីករាយជាមួយនឹងសិទ្ធិក្នុងការចូលរួមរបស់ពួកគេនៅក្រោយការបញ្ចប់កិច្ចដំណើរការនីតិវិធីទាក់ទងនឹងអង្គហេតុដែលមិនបានដាក់បញ្ចូលក៏ដោយ។

## សេចក្តីសន្និដ្ឋាន

17. អាស្រ័យដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើថា ដើម្បីជាផលប្រយោជន៍នៃយុត្តិធម៌ សូមអង្គជំនុំជម្រះសាលាដំបូងបញ្ចប់កិច្ចដំណើរការនីតិវិធី ដោយអនុលោមតាមវិធាន៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុង ចំពោះអង្គហេតុទាំងនោះ ដែលបានដកចេញពីវិសាលភាពនៃសំណុំរឿង០០២/០២៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ | **លោក សេង ប៊ុនឃាង**<br>សហព្រះរាជអាជ្ញាជាតិស្តីទី | ភ្នំពេញ | [signature] |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | [signature] |

[18] វិធាន៨៩ស្ទួនបី(៤) នៃវិធានផ្ទៃក្នុង។

[19] **D404/2/4** សាលដីកាលើបណ្តឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី, អង្គបុរេជំនុំជម្រះ, ២៤ មិថុនា ២០១១, ទំព័រ៥១-៥៥។ សូមមើលផងដែរ ឯកសារ **E284** សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៣, ២៦ មេសា ២០១៣, កថាខណ្ឌ ១១៤។